**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៣៦ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ប្រាក់បំណាច់ចៅក្រមនិងព្រះរាជអាជ្ញា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤/ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៣៩៨ ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៥ ស្តីពីឋានន្តរស័ក្តិនិងថ្នាក់សម្រាប់ចៅក្រមនិងព្រះរាជអាជ្ញា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

**សម្រេច**

**ជំពូកទី១**

**បទប្បញ្ញត្តិទូទៅ**

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលបំណងរៀបចំនិងកំណត់ប្រាក់បំណាច់ចៅក្រមនិងព្រះរាជអាជ្ញា ដើម្បីធានាបាននូវប្រសិទ្ធភាពនិងការបង្កើនផលិតភាពក្នុងប្រព័ន្ធយុត្តិធម៌ ព្រមទាំងការធានានូវសមធម៌និងសង្គតិភាពក្នុងប្រព័ន្ធបៀវត្សអនុលោមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។



www.pheakdeylaw.com

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលដៅកំណត់ប្រាក់បំណាច់ចៅក្រមនិងព្រះរាជអាជ្ញា។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះចៅក្រមនិងព្រះរាជអាជ្ញាដែលស្ថិតនៅក្រោមច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រមនិងព្រះរាជអាជ្ញា។

## ជំពូកទី២
## ប្រាក់បំណាច់ចៅក្រមនិងព្រះរាជអាជ្ញា

**មាត្រា៤.-**

ប្រាក់បំណាច់ចៅក្រមនិងព្រះរាជអាជ្ញា រួមមាន ប្រាក់បំណាច់មុខងារចៅក្រមនិងព្រះរាជអាជ្ញា ប្រាក់បំណាច់ឈ្នួលផ្ទះ ប្រាក់បំណាច់អធិមូលជីវភាព ប្រាក់បំណាច់សម្រាប់ផ្លាស់ប្តូរទីតាំងការងារ ប្រាក់ថ្លៃព្យាបាលនៅក្នុងមន្ទីរពេទ្យ និងប្រាក់ឧបត្ថម្ភសម្រាប់ព្យាបាលជំងឺប្រចាំកាយរយៈពេលយូរបស់ចៅក្រមនិងព្រះរាជអាជ្ញា។

ប្រាក់បំណាច់ចៅក្រមនិងព្រះរាជអាជ្ញា ត្រូវបានបើកផ្តល់ប្រចាំខែតាមការកំណត់ដូចខាងក្រោម៖

| ល.រ | បរិយាយ | ប្រាក់បំណាច់(រៀល) |
|---|---|---|
| ១ | - ប្រធានតុលាការកំពូល<br>- អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល | ១០ ០០០ ០០០ |
| ២ | - អនុប្រធានតុលាការកំពូល<br>- ប្រធានសភានៃតុលាការកំពូល<br>- អគ្គព្រះរាជអាជ្ញារងអមតុលាការកំពូល<br>- ប្រធានសាលាឧទ្ធរណ៍<br>- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ | ៤ ៥០០ ០០០ |
| ៣ | - ចៅក្រមតុលាការកំពូល<br>- ព្រះរាជអាជ្ញាអមតុលាការកំពូល<br>- អនុប្រធានសាលាឧទ្ធរណ៍<br>- ប្រធានសភានៃសាលាឧទ្ធរណ៍<br>- អគ្គព្រះរាជអាជ្ញារងអមសាលាឧទ្ធរណ៍ | ៤ ០០០ ០០០ |
| ៤ | - ចៅក្រមសាលាឧទ្ធរណ៍<br>- ប្រធានសាលាដំបូង<br>- ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍<br>- ព្រះរាជអាជ្ញាអមសាលាដំបូង<br>- ព្រះរាជអាជ្ញាបម្រើការងារនៅក្រសួងយុត្តិធម៌ | ៣ ៥០០ ០០០ |
| ៥ | - អនុប្រធានសាលាដំបូង<br>- ប្រធានតុលាការជំនាញនៃសាលាដំបូង<br>- ព្រះរាជអាជ្ញារងអមសាលាដំបូង | ៣ ២០០ ០០០ |
| ៦ | - ចៅក្រមសាលាដំបូង | ៣ ០០០ ០០០ |
| ៧ | - ចៅក្រមកម្មសិក្សា<br>- ព្រះរាជអាជ្ញារងកម្មសិក្សា | ១ ៥០០ ០០០ |

**មាត្រា៥.-**

ការបើកផ្តល់ប្រាក់បំណាច់ចៅក្រមនិងព្រះរាជអាជ្ញា រួមទាំងការបើកផ្តល់ប្រាក់បៀវត្សប្រចាំខែ ត្រូវអនុវត្តតាមប្រព័ន្ធធនាគារ។

ចៅក្រមនិងព្រះរាជអាជ្ញាដែលទទួលមុខតំណែងលើសពីមួយ មានសិទ្ធិជ្រើសរើសប្រាក់បំណាច់តែមួយប៉ុណ្ណោះ។



www.pheakdeylaw.com

**មាត្រា៦.-**

ប្រាក់បំណាច់ចៅក្រមនិងព្រះរាជអាជ្ញាដែលបានកំណត់ក្នុងអនុក្រឹត្យនេះ ត្រូវចាប់អនុវត្តពីថ្ងៃទី១ ខែមេសា ឆ្នាំ២០១៦តទៅ។

ការកែសម្រួលប្រាក់បំណាច់ចៅក្រមនិងព្រះរាជអាជ្ញា ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៣

## អវសានប្បញ្ញត្តិ

**មាត្រា៧.-**

អនុក្រឹត្យលេខ១១៣ អនក្រ.បក ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០២ ស្ដីពីប្រាក់ឧបត្ថម្ភចៅក្រម ត្រូវទុកជានិរាករណ៍ចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០១៦។

**មាត្រា៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មិនា ឆ្នាំ២០១៦

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

| រដ្ឋមន្ត្រី<br>ក្រសួងយុត្តិធម៌ | រដ្ឋមន្ត្រី<br>ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | រដ្ឋមន្ត្រី<br>ក្រសួងមុខងារសាធារណៈ |
|---|---|---|
| **អង្គ វង្សវឌ្ឍនា** | **អូន ព័ន្ធមុនីរ័ត្ន** | **ពេជ្រ ប៊ុនធិន** |

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



www.pheakdeylaw.com